ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២០៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើមុខទំនិញមួយចំនួន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ២១០ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន
- បានឃើញ អនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន

- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ លើមុខទំនិញមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូក ១

## ការកែសម្រួលអត្រាពន្ធគយលើមុខទំនិញមួយចំនួន

**មាត្រា ១** .- ត្រូវបានបន្ថយអត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួនដូចខាងក្រោម÷

- ពី ៧% មក ០% លើមុខទំនិញវត្ថុធាតុដើមសម្រាប់ផលិតកម្មចំណីអាហារនិងភេសជ្ជៈ និងប្រព័ន្ធសូឡា ចំនួន **១៣ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ២៨០១.២០.០០ ២៩១៦.១៩.០០ ២៩១៨.១៩.០០ ២៩២៤.២៩.១០ ២៩២៩.៩០.១០ ២៩៣៤.៩៩.៩០ ៣៣០២.១០.១០ ៣៣០២.១០.២០ ៣៣០២.១០.៩០ ៣៣០២.៩០.០០ ៨៥៤១.៤០.២១ ៨៥៤១.៤០.២២ និង ៨៥៤១.៤០.២៩។
- ពី ១៥% មក ០% លើមុខទំនិញឧបករណ៍ និងគ្រឿងម៉ាស៊ីនកែច្នៃសំខាន់ៗ ដែលបម្រើការដល់សង្វាក់ផលិតកម្មនានា ចំនួន **៥៦ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷
  ៨៤១៩.៣២.១០ ៨៤១៩.៣២.២០ ៨៤២៣.២០.១០ ៨៤២៣.២០.២០ ៨៤២៣.៣០.១០
  ៨៤២៣.៣០.២០ ៨៤៣៤.១០.១០ ៨៤៣៤.១០.២០ ៨៤៣៤.២០.១០ ៨៤៣៤.២០.២០
  ៨៤៣៧.៨០.៣០ ៨៤៣៧.៨០.៤០ ៨៤៣៨.៨០.១១ ៨៤៣៨.៨០.១២ ៨៤៣៨.៩០.១២
  ៨៤៣៨.៩០.២២ ៨៤៣៩.១០.០០ ៨៤៣៩.២០.០០ ៨៤៣៩.៣០.០០ ៨៤៣៩.៩១.០០
  ៨៤៣៩.៩៩.០០ ៨៤៥៣.១០.១០ ៨៤៥៣.១០.២០ ៨៤៥៣.២០.១០ ៨៤៥៣.២០.២០
  ៨៤៥៣.៨០.១០ ៨៤៥៣.៨០.២០ ៨៤៥៣.៩០.០០ ៨៤៥៥.១០.០០ ៨៤៥៥.២១.០០
  ៨៤៥៥.២២.០០ ៨៤៥៥.៣០.០០ ៨៤៧៧.១០.១០ ៨៤៧៧.១០.៣១ ៨៤៧៧.១០.៣៩
  ៨៤៧៧.២០.១០ ៨៤៧៧.២០.២០ ៨៤៧៧.៣០.០០ ៨៤៧៧.៤០.១០ ៨៤៧៧.៤០.២០
  ៨៤៧៧.៥១.០០ ៨៤៧៧.៥៩.១០ ៨៤៧៧.៥៩.២០ ៨៤៧៧.៨០.១០ ៨៤៧៧.៨០.២០
  ៨៤៧៧.៨០.៣១ ៨៤៧៧.៨០.៣៩ ៨៤៧៧.៨០.៤០ ៨៤៧៩.៨២.១០ ៨៤៧៩.៨២.២០
  ៩០២៧.២០.១០ ៩០២៧.៣០.១០ ៩០២៧.៥០.១០ ៩០២៧.៨០.១០ ៩០២៧.៨០.៣០
  និង ៩០២៧.៨០.៤០ ។
- ពី ១៥% មក ៧% លើមុខទំនិញវត្ថុធាតុដើម និងម៉ាស៊ីនកែច្នៃសំខាន់ៗ បម្រើការឱ្យសង្វាក់ផលិតកម្មនានា ចំនួន **៦០ បន្ទាត់ពន្ធ** នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ១៣០២.៣៩.១១
  ១៣០២.៣៩.១២ ១៣០២.៣៩.១៣ ១៣០២.៣៩.១៩ ៧៣២៦.១១.០០ ៧៣២៦.២០.៥០
  ៧៣២៦.២០.៦០ ៧៣២៦.៩០.២០ ៨៤២២.១១.០០ ៨៤២២.១៩.០០ ៨៤២២.២០.០០
  ៨៤២២.៣០.០០ ៨៤២២.៤០.០០ ៨៤៣៥.១០.១០ ៨៤៣៥.១០.២០ ៨៤៣៥.៩០.១០
  ៨៤៣៥.៩០.២០ ៨៤៦០.១២.០០ ៨៤៦០.១៩.០០ ៨៤៦០.២២.០០ ៨៤៦០.២៣.០០

៨៤៦០.២៤.០០ ៨៤៦០.២៩.១០ ៨៤៦០.២៩.២០ ៨៤៦០.៣១.១០ ៨៤៦០.៣១.៩០
៨៤៦០.៣៩.១០ ៨៤៦០.៣៩.២០ ៨៤៦០.៤០.១០ ៨៤៦០.៤០.២០ ៨៤៦០.៩០.១០
៨៤៦០.៩០.២០ ៨៤៦១.២០.១០ ៨៤៦១.២០.២០ ៨៤៦១.៣០.១០ ៨៤៦១.៣០.២០
៨៤៦១.៤០.១០ ៨៤៦១.៤០.២០ ៨៤៦១.៥០.១០ ៨៤៦១.៥០.២០ ៨៤៦១.៩០.១១
៨៤៦១.៩០.១៩ ៨៤៦១.៩០.៩១ ៨៤៦១.៩០.៩៩ ៨៤៦២.១០.១០ ៨៤៦២.១០.២០
៨៤៦២.២១.០០ ៨៤៦២.២៩.១០ ៨៤៦២.២៩.២០ ៨៤៦២.៣១.០០ ៨៤៦២.៣៩.១០
៨៤៦២.៣៩.២០ ៨៤៦២.៤១.០០ ៨៤៦២.៤៩.១០ ៨៤៦២.៤៩.២០ ៨៤៦២.៩១.០០
៨៤៦២.៩៩.១០ ៨៤៦២.៩៩.២០ ៨៤៦២.៩៩.៥០ និង ៨៤៦២.៩៩.៦០។

- ពី ៣៥% មក ៧% លើមុខទំនិញអាល់កុលសម្លាប់មេរោគ និងមុខទំនិញមួយចំនួនទៀតដែលគាំទ្រដល់វិស័យឧស្សាហកម្ម ចំនួន ០៦ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ២៥០១.០០.១០ ២២០៧.២០.១១ ២២០៧.២០.១៩ ២២០៧.២០.៩០ ៣៨១៤.០០.០០ និង ៤២០៣.២៩.១០។
- ពី ៣៥% មក ១៥% លើមុខទំនិញជាវត្ថុធាតុដើម និងធាតុចូលផលិតកម្ម ចំនួន ០៤ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាឆ្នាំ ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ១៨០៥.០០.០០ ២២០៧.១០.០០ ៨៥១៦.៦០.១០ និង ៨៥១៦.៧៩.១០។

## ឧបសម្ព័ន្ធ ២

## ការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន

**មាត្រា ២.-** ត្រូវបានបន្ថយអត្រាអាករពិសេសលើមុខទំនិញនាំចូលមួយចំនួនដូចខាងក្រោម÷

- ពី ១០% មក ០% លើមុខទំនិញ ប្រេងរំអិលប្រើប្រាស់ក្នុងវិស័យវាយនភ័ណ្ឌ ម៉ាស៊ីនលាងចាន និងទោចក្រយាន ចំនួន ១៦ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ២៧១០.១៩.៤៤ ៣៤០៣.១១.១១ ៣៤០៣.១១.១៩ ៣៤០៣.១១.៩០ ៣៤០៣.៩១.១១ ៣៤០៣.៩១.១៩ ៣៤០៣.៩១.៩០ ៣៩២៦.២០.៦០ ៣៩២៦.៩០.៣២ ៣៩២៦.៩០.៤១ ៣៩២៦.៩០.៤២ ៣៩២៦.៩០.៦០ ៨៤២២.១១.០០ ៨៤២២.១៩.០០ ៨៧១២.០០.២០ និង ៨៧១២.០០.៣០។
- ពី ១០% មក ៥% លើមុខទំនិញសម្ភារៈអគ្គិសនីប្រើប្រាស់ក្នុងផ្ទះ ចំនួន ០៥ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៨៤១៨.១០.១១ ៨៤១៨.១០.១៩ ៨៤១៨.២១.១០ ៨៤១៨.២១.៩០ និង ៨៤១៨.២៩.០០។
- ពី ២៥% មក ០% លើមុខទំនិញ ប្រេងរំអិលជាធាតុចូលក្នុងសង្វាក់ផលិតកម្មនានា ចំនួន ០៨ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ៣៤០៣.១៩.១១ ៣៤០៣.១៩.១២ ៣៤០៣.១៩.១៩ ៣៤០៣.១៩.៩០ ៣៤០៣.៩៩.១១ ៣៤០៣.៩៩.១២ ៣៤០៣.៩៩.១៩ និង ៣៤០៣.៩៩.៩០។

- ពី ៣៥% មក ០% លើមុខទំនិញអាល់កុលសម្លាប់មេរោគប្រើប្រាស់ក្នុងវិស័យសុខាភិបាល ចំនួន ០៣ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ២២០៧.២០.១១ ២២០៧.២០.១៩ និង ២២០៧.២០.៩០។
- ពី ៣៥% មក ១៥% លើមុខទំនិញមេស្រាដែលមានជាតិអាល់កុលចាប់ពី៨០ដឺក្រេ ចំនួន ០១ បន្ទាត់ពន្ធនៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ក្នុងទីតាំងរងលេខ÷ ២២០៧.១០.០០។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២១ តទៅ។

ថ្ងៃ ពុធ ២ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>កន្លែងទទួល÷</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យ សម្ដេច/ឯកឧត្ដម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ